សេចក្តីសង្ខេប

# យុទ្ធសាស្ត្រចតុកោណ

## ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព

## កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

## ដំណាក់កាលទី៤

## របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា

Domnakseuksa

# យុទ្ធសាស្ត្រចតុកោណ

## ❀គោលដៅជាយុទ្ធសាស្ត្រ ទាំង០៤៖

ទី១.ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ
ទី២.បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ជូនដល់ប្រជាជនកម្ពុជា ពិសេសយុវជន
ទី៣.សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០% និងការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ
ទី៤.បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ❀វិស័យអាទិភាព ទាំង០៤

- ទី១. មនុស្ស
- ទី២. ផ្លូវ
- ទី៣. ទឹក
- ទី៤. ភ្លើង

# យុទ្ធសាស្ត្រចតុកោណ

## រចនាសម្ព័ន្ធយុទ្ធសាស្ត្រចតុកោណ

១.ស្នូលយុទ្ធសាស្ត្រចតុកោណ "ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច"

២.បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

៣.ចតុកោណយុទ្ធសាស្ត្រទាំង៤

៤.មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ

# ១.ស្ទូលយុទ្ធសាស្រ្តចតុកោណ
## “ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច”

ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

- ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន
- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ
- ការពង្រឹងប្រសិទ្ធភាពការអនុវត្តការងារ
- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

# ១.ស្នូលយុទ្ធសាស្ត្រចតុកោណ
## "ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច"

- **គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច៖** ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល និងផ្តោតលើការកសាងជាតិ។
- **នីតិកាលកន្លងទៅសម្រេចបាន៖** វឌ្ឍនភាពជាមូលដ្ឋានក្នុងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។
- **បញ្ហាប្រឈម៖** ជួបប្រទះបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការត្រួតមុខងារនិងដែនសមត្ថកិច្ច, ការជ្រើសរើសនិងការលើកទឹកចិត្តមន្ត្រីរាជការ, ប្រព័ន្ធគណនេយ្យភាព, សមត្ថភាពជំនាញនិងវិជ្ជាជីវៈមន្ត្រីរាជការ, គម្លាតរវាងគោលនយោបាយនិងការអនុវត្ត, ការផ្តល់សេវាយុត្តិធម៌, និងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។

# ១.១. ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

- **ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

ទី១.ការធ្វើវិចារណកម្មមុខងារ និងភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័ន

ទី២.ការពង្រឹងភាពជាអ្នកដឹកនាំ, ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសាមគ្គីភាពផ្ទៃក្នុងស្ថាប័ន, ការរៀបចំនិងអនុវត្តហ្វឹកហ្វឺនក្រមប្រតិបត្តិសម្រាប់បំពេញការងារ,និងការសម្រិតសម្រាំងកេមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អប្រសើរ សម្រាប់ការតែងតាំងមុខតំណែងដឹកនាំ នៅក្នុងមុខងារសាធារណៈ

ទី៣.ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស/តែងតាំង ការដំឡើងថ្នាក់/ឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈ និងអង្គភាពសាធារណៈ

ទី៤.ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន,ហេដ្ឋារចនាសម្ព័ន្ធការងារ,ក្របខណ្ឌអភិវឌ្ឍមូលធនមនុស្ស និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

ទី៥.ការបន្តកែទម្រង់កងកម្លាំងប្រដាប់អាវុធ។

Domnakseuksa

# ១.២.ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

➢ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១.ការសម្រួចយុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងក្របខណ្ឌ "មិនហ៊ាន មិនអាច និងមិនចង់" ប្រព្រឹត្តអំពើពុករលួយ

ទី២.ការពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយជាតិ

ទី៣.ការជំរុញឱ្យមានការចូលរួមពីសំណាក់ប្រជាជន ក្នុងដំណើរការនៃការអភិវឌ្ឍ ការរៀបចំគោលនយោបាយ និងការអនុវត្ត

ទី៤.ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដំណោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

ទី៥.ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មក្នុងវិស័យសាធារណៈ

ទី៦.ការពង្រឹងប្រសិទ្ធភាពរៀបចំ និងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍។

Domnakseuksa

# ១.៣.ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

- ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖

  ទី១.បន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល/កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បង្កើនប្រាក់សោធនជូននិវត្តជន និងអតីតយុទ្ធជន ដោយការបើកផ្តល់តាមធនាគារ ក្នុងរយៈពេល ២សប្តាហ៍ម្តង

  ទី២.ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ធនធាន និងការចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ

  ទី៣.ការជំរុញនវានុវត្តន៍ និងរដ្ឋបាលឯកភាព នៅក្នុងកម្រិតក្រុង-ស្រុក-ខណ្ឌ ខេត្ត-រាជធានី ដើម្បីធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងប្រើប្រាស់ធនធាន

  ទី៤.ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដោយប្រើប្រាស់សូចនាករគន្លឹះ( KEY PERFORMANCE INDICATORS )

  ទី៥.ការដាក់ឱ្យប្រើប្រាស់យន្តការតាមដាន និងវាយតម្លៃ

  ទី៦.ការពង្រឹងយន្តការចែករំលែកនិងផ្លាស់ប្តូរព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតទូទាំងប្រទេស

  ទី៧.ការលើកម្ពស់សេវាយុត្តិធម៌ និងពង្រឹងជំនឿទុកចិត្តពីសាធារណៈជនលើវិស័យយុត្តិធម៌។



Domnakseuksa